Delete and use school letterhead

Delete and type date

Delete and type parent/carer name and address

## **ទីកន្លែងចូលរៀនថ្នាក់ YEAR 7 ឆ្នាំក្រោយ**

**PLACEMENT IN YEAR 7 NEXT YEAR**

ឈ្មោះសិស្ស: Delete and type name of student

ឆ្នាំប្រក្រតិទិនសំរាប់ទីកន្លែងចូលរៀនថ្នាក់ Year 7: Delete and type calendar year for placement in Year 7

ថ្ងៃខែដែលត្រូវបញ្ជូន *ពាក្យសុំចុះឈ្មោះដើម្បីចូលរៀន:* Delete and type date for return of Application to enrol

លេខទូរស័ព្ទសាលាប្រសិនបើលោកអ្នកត្រូវការជំនួយ: Delete and type school telephone number

ជូនចំពោះមាតាបិតា / អ្នកមើលថែ

សូមអរគុណលោកអ្នកចំពោះការបញ្ចេញនូវការចាប់អារម្មណ៍ សំរាប់ទីកន្លែងចូលរៀនរបស់កូនលោកអ្នកដូចមានឈ្មោះខាងលើនេះនៅថ្នាក់ Year 7 នៅសាលារៀននេះ។

ស្របទៅតាមការបញ្ចេញនូវការចាប់អារម្មណ៍របស់លោកអ្នក យើងបានសំគាល់ទុកកូនរបស់លោកអ្នកសំរាប់គោលបំណងទីកន្លែងចូលរៀននៅក្នុងបញ្ជីចុះឈ្មោះរបស់យើងឆ្នាំក្រោយ។ លោកអ្នកប្រហែលជាបានជ្រាបហើយថា រហូតទាល់តែសាលារៀនបានយល់ព្រមទទួលពាក្យសុំចុះឈ្មោះដែលបានបំពេញសព្វគ្រប់ ដូច្នេះការចុះឈ្មោះរបស់កូនលោកអ្នកមិនទាន់បានបញ្ចប់នៅឡើយ។

ប្រសិនបើលោកអ្នកប្រាថ្នាបន្តការដាក់ពាក្យសុំចុះឈ្មោះនេះ សូមបំពេញជា**ភាសាអង់គ្លេស**នូវ *ពាក្យសុំចុះឈ្មោះចូលរៀននៅក្នុងសាលារៀនរដ្ឋ NSW (Application to enrol in a NSW government school)* ដែលភ្ជាប់មកជាមួយនេះ ហើយបញ្ជូនពាក្យសុំនេះមកឲ្យខ្ញុំវិញឲ្យបានទាន់ថ្ងៃខែដូចមានចុះខាងនេះ។

សូមកត់ចំណាំៈ

- នេះគឺជាការចាំបាច់ដែលលោកអ្នកត្រូវឆ្លើយនូវគ្រប់ទាំងសំណួរនៅក្នុងពាក្យសុំ លើកលែងតែអំពីការងារ និងការអប់រំរបស់លោកអ្នក។
- ប្រសិនបើយើងមិនបានទទួលពាក្យសុំដើម្បីចុះឈ្មោះចូលរៀនរបស់លោកអ្នកទាន់ថ្ងៃខែដូចមានចុះខាងនេះទេ យើងនឹងសន្មត់ថាលោកអ្នកឈប់មានការចាប់អារម្មណ៍ទៀតហើយ ហើយសិស្សផ្សេងទៀតនឹងត្រូវបានអញ្ជើញឲ្យដាក់ពាក្យសុំ។
- ប្រសិនបើលោកអ្នកដាក់ពាក្យសុំនេះ ក៏ប៉ុន្តែក្រោយមកបានផ្លាស់ប្តូរគំនិតរបស់លោកអ្នក ឬប្រសិនបើកាលៈទេសៈរបស់លោកអ្នកផ្លាស់ប្តូរ ហើយលោកអ្នកឈប់ប្រាថ្នាបន្តការចុះឈ្មោះ សូមទាក់ទងជាមួយសាលារៀនឲ្យបានភ្លាម ដែលអាចធ្វើទៅបាន ដើម្បីឲ្យយើងអាចទាក់ទងជាមួយសិស្សផ្សេងទៀតដែលមានឈ្មោះនៅក្នុងបញ្ជីរង់ចាំរបស់យើង។

ពាក្យសុំរបស់លោកអ្នកនឹងត្រូវបានពិនិត្យមើលឡើងវិញ ហើយចាត់ថែងក្នុងអាទិភាពខ្ពស់បំផុត។ ប្រសិនបើពាក្យសុំរបស់លោកអ្នកត្រូវបានទទួលយកលិខិតបញ្ជាក់ជាផ្លូវការអំពីការចុះឈ្មោះមួយនឹងបានផ្ញើជូនលោកអ្នក។ នៅក្នុងកាលៈទេសៈខ្លះ យើងប្រហែលជាត្រូវតាមដានបន្តជាមួយលោកអ្នកលើចំណុចសំខាន់ខ្លះ។ នៃព័ត៌មានដែលលោកអ្នកបានផ្តល់នៅក្នុងពាក្យសុំរបស់លោកអ្នក។ ប្រសិនបើការនេះកើតមានឡើង យើងនឹងទាក់ទងជាមួយលោកអ្នក។

ប្រសិនបើលោកអ្នកត្រូវការជំនួយដើម្បីបំពេញពាក្យសុំ *Application to enrol in a NSW government school* សូមទាក់ទងជាមួយសាលាបឋមសិក្សាក្នុងតំបន់របស់លោកអ្នក ឬទូរស័ព្ទមកយើងដើម្បីធ្វើការណាត់ពេលនិយាយជាមួយបុគ្គលិកសាលាមធ្យមសិក្សារបស់យើង។ ប្រសិនបើលោកអ្នកមានសំណួរណាមួយ សូមទាក់ទងជាមួយសាលារៀន។ ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសាដើម្បីជួយលោកអ្នក លោកអ្នកអាចទូរស័ព្ទទៅកិច្ចបំរើបកប្រែភាសាតាមទូរស័ព្ទ លេខ 131 450 រួចស្នើសុំអ្នកបកប្រែមួយរូបដែលចេះនិយាយភាសារបស់លោកអ្នក។ អ្នកបកប្រែភាសានោះនឹងទូរស័ព្ទទៅសាលារៀន ហើយនៅរង់ចាំតាមទូរស័ព្ទដើម្បីជួយលោកអ្នកនៅក្នុងការសន្ទនា។ លោកអ្នកនឹងមិនត្រូវគេគិតថ្លៃចំពោះកិច្ចបំរើនេះទេ។

សូមអរគុណចំពោះការជួយជ្រោមជ្រែងរបស់លោកអ្នក។

ដោយនូវសេចក្តីគោរពអំពីខ្ញុំ

នាយកសាលា

Principal